រាជបណ្ឌិត្យសភាកម្ពុជា

# រដ្ឋសភាកម្ពុជា និង ការអនុវត្តគោលការណ៍បែងចែកអំណាច (១៩៩៣-២០០៨)

# CAMBODIAN NATIONAL ASSEMBLY AND IMPLEMENTATION OF PRINCIPLE OF POWER SEPARATION (1993-2008)

គិង តា

និក្ខេបបទបណ្ឌិតវិទ្យាសាស្ត្រនយោបាយ

២០១១

រាជបណ្ឌិត្យសភាកម្ពុជា

# រដ្ឋសភាកម្ពុជា និង ការអនុវត្តគោលការណ៍ បែងចែកអំណាច (១៩៩៣-២០០៨)

# CAMBODIAN NATIONAL ASSEMBLY AND IMPLEMENTATION OF PRINCIPLE OF POWER SEPARATION (1993-2008)

គិន ភា

និក្ខេបបទថ្នាក់បណ្ឌិត វិទ្យាសាស្ត្រនយោបាយ

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត សុខ ទូច

២០១១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia

Académie Royale du Cambodge

លេខ ២៣៦/១១ របសក

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឱ្យបេក្ខជនបណ្ឌិតការពារបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិត

## ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣/០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល បទបញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩។
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ/បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃរាជបណ្ឌិត្យសភាកម្ពុជា។
- យោងចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ លើលិខិតស្នើសុំរបស់រាជបណ្ឌិត្យសភាកម្ពុជា ស្តីពីគម្រោងបណ្តុះបណ្តាលថ្នាក់បណ្ឌិត វគ្គទី១។
- យោងគោលការណ៍ស្តីពីលក្ខខណ្ឌជ្រើសរើស និងបណ្តុះបណ្តាលថ្នាក់បណ្ឌិត នៅរាជបណ្ឌិត្យសភាកម្ពុជា ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨។

## សម្រេច

**ប្រការ ១៖** អនុញ្ញាតឱ្យបេក្ខជន **តិន នា** បេក្ខជនបណ្ឌិត វគ្គទី១ ឯកទេស **វិទ្យាសាស្ត្រនយោបាយ** នៃរាជបណ្ឌិត្យសភាកម្ពុជា ការពារបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១។

**ប្រការ ២៖** គណៈកម្មការវាយតម្លៃនិក្ខេបបទថ្នាក់បណ្ឌិត ផ្នែកបណ្តុះបណ្តាល និង ស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា និង សាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ មិថុនា ឆ្នាំ២០១១

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**បណ្ឌិតសភាចារ្យ ខ្លូត ធីដា**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា

Tel/Fax: (855) 23 890 180 Website: www.rac-academy.edu.kh, E-mail: info@rac-academy.edu.kh, P.O Box 531 Phnom Penh, Cambodia

# មាតិកាអត្ថបទ


មាតិកា ........................................ i

ឧទ្ទិសស្នាដៃ ........................................ vi

សេចក្តីថ្លែងអំណរគុណ ........................................ vii

អំណះអំណាង ........................................ viii

មូលន័យជាភាសាខ្មែរ ........................................ ix

មូលន័យជាភាសាអង់គ្លេស ........................................ xi

សេចក្តីសង្ខេបជាភាសាខ្មែរ ........................................ xiii

សេចក្តីសង្ខេបជាភាសាអង់គ្លេស ........................................ xxv

ពាក្យប្រើជាអក្សរកាត់ ........................................ xxxiii

**អារម្ភកថា** ........................................ ១

**សេចក្តីផ្តើម** ........................................ ២

**ជំពូកទី១**

**រដ្ឋសភាកម្ពុជា មុនឆ្នាំ១៩៩៣ ក្នុងបរិបទប្រវត្តិសាស្ត្រ និងនយោបាយ**

**១- បុព្វបទនៃការកកើតរដ្ឋសភានៅកម្ពុជា** ........................................ ២៤

១.១- ទិដ្ឋភាពប្រវត្តិសាស្ត្រនៃរបបគ្រប់គ្រងសង្គមកម្ពុជាមុនសង្គ្រាមលោកលើកទី២ ........................................ ២៤

១.២- បរិបទនយោបាយអន្តរជាតិ និងការតស៊ូក្នុងស្រុក ........................................ ៣៦

១.៣- កម្លាំងនយោបាយថ្មីនៅកម្ពុជា ........................................ ៤១

**២- រដ្ឋសភា ឆ្នាំ១៩៤៦-១៩៧២** ........................................ ៤៦

២.១- ការបោះឆ្នោតសភាធម្មនុញ្ញ ឆ្នាំ១៩៤៦ ........................................ ៤៦

២.២- រដ្ឋសភានីតិកាលទី១ ឆ្នាំ១៩៤៧-១៩៥១ ........................................ ៥២

២.៣- រដ្ឋសភានីតិកាលទី២ ឆ្នាំ១៩៥១-១៩៥៣ ........................................ ៥៥

២.៤- រដ្ឋសភានីតិកាលទី៣ ឆ្នាំ១៩៥៥-១៩៥៨ ........................................ ៥៧

២.៥- រដ្ឋសភានីតិកាលទី៤ ឆ្នាំ១៩៥៨-១៩៦២ ........................................ ៦៧

២.៦- រដ្ឋសភានីតិកាលទី៥ ឆ្នាំ១៩៦២-១៩៦៦ ........................................ ៦៩

២.៧- រដ្ឋសភានីតិកាលទី៦ ឆ្នាំ១៩៦៦-១៩៧២ ........................................ ៧១

**៣- រដ្ឋសភាកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧២-១៩៩៣** ........................................ ៧៦

៣.១- សភានៃរបបសាធារណរដ្ឋខ្មែរ ........................................ ៧៧

៣.២- រដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យ ........................................ ៨៦

៣.៣- រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា.......................................៩២

## ជំពូកទី ២

## ការបោះឆ្នោត និងការរៀបចំរចនាសម្ព័ន្ធរដ្ឋសភា ក្រោយឆ្នាំ១៩៩៣

**១- បម្រែបម្រួលនយោបាយឆ្ពោះទៅកាន់ការបោះឆ្នោត ឆ្នាំ១៩៩៣**.................១០២
១.១- ដំណើរការនៃការចរចាសន្តិភាព.......................................................១០៤
១.២- សន្និសីទអន្តរជាតិទីក្រុងប៉ារីសស្តីពីកម្ពុជា.......................................១០៧
១.៣- អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា..................១១១
**២- ដំណើរការប្រជាធិបតេយ្យក្រោយកិច្ចព្រមព្រៀង និងការបោះឆ្នោត ជាបន្តបន្ទាប់**.......................................................................១១៣
២.១- ការបោះឆ្នោតឆ្នាំ១៩៩៣ ៖ ការចេញដំណើរនៃលទ្ធិប្រជាធិបតេយ្យ.....................១១៥
២.២- ការបោះឆ្នោតឆ្នាំ១៩៩៨ ៖ អច្ឆរិយៈនៅទន្លេមេគង្គ......................................១៤០
២.៣- ការបោះឆ្នោតឆ្នាំ២០០៣ ៖ លទ្ធិប្រជាធិបតេយ្យនៅលើផ្លូវវែង.........................១៥៩
**៣- ការរៀបចំរចនាសម្ព័ន្ធរដ្ឋសភា**.....................................................១៦៦
១.១- ថ្នាក់ដឹកនាំរដ្ឋសភា..............................................................១៦៧
៣.២- គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា....................................................១៧៥
៣.៣- គណៈកម្មការជំនាញ..............................................................១៧៧
៣.៤- អគ្គលេខាធិការដ្ឋានរដ្ឋសភា.....................................................១៨២

## ជំពូកទី ៣

## ការប្រព្រឹត្តទៅនៃរដ្ឋសភាកម្ពុជា

**១- ការប្រជុំរបស់រដ្ឋសភា**............................................................១៨៩
១.១- សម័យប្រជុំពេញអង្គរដ្ឋសភា.....................................................១៨៩
១.២- ការបញ្ចេញមតិ...................................................................២០៦
១.៣- របៀបប្រជុំ.......................................................................២០៨
១.៤- សម័យប្រជុំរបស់រដ្ឋសភា និងបញ្ហាកូរ៉ុម.............................................២១០
**២- ដំណើរការនីតិកម្មរបស់រដ្ឋសភា**....................................................២១៥
២.១- អ្នកមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់.................................................២១៦
២.២- គោលការណ៍ច្បាប់.................................................................២១៧
២.៣- ដំណើរការពិភាក្សាច្បាប់នៅរដ្ឋសភា.................................................២១៨

២.៤- ទំនាក់ទំនងរវាងរដ្ឋសភា និងព្រឹទ្ធសភាក្នុងដំណើរការនីតិកម្ម ..........២២០
២.៥- ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ..........២២១
២.៦- ការចូលជាធរមាន និងការផ្សព្វផ្សាយច្បាប់ ..........២២៤
២.៧- ស្មារតីនៃការអនុវត្តច្បាប់ ..........២២៥
**៣- ការរៀបចំថវិការដ្ឋសភា ..........២២៨**
៣.១- ឥណទានសម្រាប់ថវិការបស់រដ្ឋសភា ..........២២៩
៣.២- ប្រាក់បំណាច់ផ្សេងៗ និងប្រាក់សោធននិវត្តន៍របស់តំណាងរាស្ត្រ ..........២៣០
៣.៣- ប្រាក់បំណាច់ និងប្រាក់បំពេញភារកិច្ចសម្រាប់អ្នកតំណាងរាស្ត្រ ..........២៣១
**៤- សមាជិករដ្ឋសភា ..........២៣៣**
៤.១- អាណត្តិឯកាជ្យសមាជិករដ្ឋសភា ..........២៣៤
៤.២- ដែនកំណត់ និងវិសមិតភាពសមាជិករដ្ឋសភា ..........២៣៩
៤.៣- អភ័យឯកសិទ្ធិសភានៃសមាជិករដ្ឋសភា ..........២៤១
៤.៤- សិទ្ធិ និងកាតព្វកិច្ចសមាជិករដ្ឋសភា ..........២៤៥
៤.៥- បទវិន័យ និងទណ្ឌកម្មចំពោះសមាជិករដ្ឋសភា ..........២៤៧
៤.៦- ការទទួលខុសត្រូវរបស់សមាជិកសភា ..........២៤៩
៤.៧- កម្រិតវប្បធម៌របស់សមាជិករដ្ឋសភា ..........២៥២
**៥- ទំនាក់ទំនងរបស់រដ្ឋសភាជាមួយស្ថាប័ននានា ..........២៥៤**
៥.១- ទំនាក់ទំនងរវាងរដ្ឋសភា និងព្រះមហាក្សត្រ ..........២៥៤
៥.២- ទំនាក់ទំនងជាមួយរដ្ឋាភិបាល ..........២៦០
៥.៣- ទំនាក់ទំនងសមាជិករដ្ឋសភាជាមួយគណបក្សនយោបាយ ..........២៧០
៥.៤- ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ..........២៧៥
៥.៥- ទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិល ..........២៨៣
៥.៦- រដ្ឋសភាក្នុងការងារទំនាក់ទំនងអន្តរជាតិ ..........២៨៦

## ជំពូកទី ៤

## រដ្ឋសភាកម្ពុជាក្នុងបរិបទនយោបាយ និងការអនុវត្តគោលការណ៍បែងចែកអំណាច

**១- ការប្រកួតប្រជែងនយោបាយតាមរយៈរដ្ឋសភា ឆ្នាំ១៩៩៣-១៩៩៨ ..........២៩០**
១.១- ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ..........២៩០
១.២- ករណីលោក សម រង្ស៊ី និងព្រះអង្គម្ចាស់ នរោត្តម សិរីវឌ្ឍ ..........២៩៣

១.៣- ព្រឹត្តិការណ៍គប់គ្រាប់បែកនៅមុខរដ្ឋសភា ថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៩៧ ................ ៣០៣

**២- រដ្ឋសភា និង ព្រឹត្តិការណ៍ថ្ងៃទី០៥-០៦ កក្កដា ១៩៩៧** ........................................ ៣០៤

២.១- ស្ថានការណ៍នយោបាយមុនព្រឹត្តិការណ៍ថ្ងៃទី៥-៦ កក្កដា ១៩៩៧......................... ៣០៦

២.២- ឥទ្ធិពលនៃជម្លោះនយោបាយទៅលើរដ្ឋសភា ................................................ ៣១២

២.៣- ការប្រយុទ្ធគ្នានៅទីក្រុងភ្នំពេញ ថ្ងៃទី៥-៦ កក្កដា ១៩៩៧ ............................. ៣១៥

២.៤- ស្ថានការណ៍នយោបាយក្រោយការផ្ទុះអាវុធ.................................................. ៣១៨

២.៥- ប្រតិកម្មអន្តរជាតិចំពោះព្រឹត្តិការណ៍ថ្ងៃ០៥-០៦ កក្កដា ១៩៩៧........................ ៣២០

**៣- ការបោះឆ្នោតកញ្ចប់នៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែម និងវិសោធនកម្ម ៥០%+១**...... ៣២៥

៣.១- បរិបទនយោបាយ.................................................................................. ៣២៥

៣.២- ទិដ្ឋភាពច្បាប់ និងទិដ្ឋភាពនយោបាយនៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែម ....................... ៣២៧

៣.៣- ការតថ្លៃអំណាច និងការបោះឆ្នោតកញ្ចប់ ..................................................... ៣៣៣

៣.៤- វិសោធនកម្មរដ្ឋធម្មនុញ្ញ ៥០%+១ ........................................................... ៣៤០

**៤- តួនាទី និង សិទ្ធិអំណាចរបស់រដ្ឋសភា**........................................................... ៣៤៦

៤.១- តួនាទី និងអំណាចសើរើរដ្ឋធម្មនុញ្ញ............................................................ ៣៤៩

៤.២- តួនាទី និងសិទ្ធិអំណាចក្នុងការអនុម័តច្បាប់ ................................................ ៣៥៣

៤.៣- អំណាចហិរញ្ញវត្ថុ.................................................................................. ៣៥៣

៤.៤- អំណាចយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ......................... ៣៥៨

៤.៥- អំណាចក្នុងការផ្តល់សេចក្តីទុកចិត្ត ត្រួតពិនិត្យ និងរំលាយរដ្ឋាភិបាល ..................... ៣៥៩

៤.៦- អំណាចតែងតាំង និង បណ្តេញមន្ត្រីជាន់ខ្ពស់នៃរដ្ឋបាលអចិន្ត្រៃយ៍.......................... ៣៦៣

៤.៧- អំណាចក្នុងនយោបាយការបរទេស ............................................................ ៣៦៤

**សេចក្តីសន្និដ្ឋាន**........................................................................................ ៣៦៩

**គន្ថនិទ្ទេស** .............................................................................................. ៣៧៣

**ឯកសារឧបសម្ព័ន្ធ**........................................................................................ ៣៨៥

# ឧទ្ទិសស្នាដៃ

ខ្ញុំបាទ **គិន នា** សូមឧទ្ទិសស្នាដៃនេះជូនចំពោះ ៖

- ប្រាជ្ញព្រឹទ្ធ បណ្ឌិត កវី បុព្វបុរសខ្មែរគ្រប់ជំនាន់ ដែលបានបន្សល់ទុកនូវស្នាដៃដ៏មានតម្លៃ ឱ្យជនានុជនខ្មែរជំនាន់ក្រោយ។

- វិញ្ញាណខ័ន្ធនៃប្រជាពលរដ្ឋខ្មែរ និងបុព្វការីជនទាំងអស់ដែលបានបូជាជីវិតដើម្បីបុព្វហេតុជាតិ សាសនា និងប្រជាជន។

- មន្ត្រី បុគ្គលិករាជការ យុទ្ធជន យុទ្ធនារី ព្រមទាំងប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលបានបូជាជីវិតដើម្បីបុព្វហេតុសន្តិភាព ការបង្រួបបង្រួមជាតិ និងសេចក្ដីរុងរឿងនៃប្រទេសជាតិទាំងមូល ។

# មូលន័យ

រដ្ឋសភានៃប្រទេសកម្ពុជាមានកំណើតដំបូងនៅឆ្នាំ១៩៤៧ ដែលជាផ្លែផ្កានៃរដ្ឋធម្មនុញ្ញដំបូងបំផុតរបស់ប្រទេស ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៤៧។ ចាប់ពីឆ្នាំ១៩៤៧ មក ប្រទេសកម្ពុជាមានការរៀបចំការបោះឆ្នោតជ្រើសតាំងរដ្ឋសភាជាបន្តបន្ទាប់ ចំនួន ១២ លើក រួមមាន ៖ លើកទី១ បោះឆ្នោតនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៧, លើកទី២ បោះឆ្នោតនៅថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ១៩៥១, លើកទី៣ បោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥, លើកទី៤ បោះឆ្នោតនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៨, លើកទី៥ បោះឆ្នោតនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៦២, លើកទី៦ បោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៦៦, លើកទី៧ បោះឆ្នោតនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៧២, លើកទី៨ បោះឆ្នោតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦, លើកទី៩ បោះឆ្នោតនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ ១៩៨១, លើកទី១០ បោះឆ្នោតនៅថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣, លើកទី១១ បោះឆ្នោតនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ និងលើកទី១២ បោះឆ្នោតនៅថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០០៣។

និក្ខេបបទនេះ មានគោលបំណងសិក្សាពីប្រវត្តិ និងការវិវត្តនៃស្ថាប័នរដ្ឋសភាកម្ពុជាតាំងពីឆ្នាំ ១៩៤៧ មកដល់ឆ្នាំ២០០៨។ មានចំណោទបញ្ហាមួយចំនួន ដែលបានលើកឡើងក្នុងនិក្ខេបបទនេះ រួមមាន ៖ តើក្នុងដំណាក់កាលដំបូងនៃការកកើតឡើងនេះ រដ្ឋសភាកម្ពុជាបានពើបប្រទះនូវការលំបាកអ្វីខ្លះ? តើការរៀបចំរចនាសម្ព័ន្ធរដ្ឋសភាផ្អែកលើមូលដ្ឋានអ្វី? តើហេតុអ្វី បានជារដ្ឋសភាជួបការលំបាកក្នុងបញ្ហាក្វ័រុមប្រជុំ ហើយគេដោះស្រាយបញ្ហាទាំងនោះដោយរបៀបណា? ជាមួយគ្នានេះដែរ យើងនឹងពិនិត្យមើលថា តើដំណើរការនីតិកម្មប្រព្រឹត្តទៅយ៉ាងដូចម្ដេច? តើច្បាប់ដែលរដ្ឋសភាបានអនុម័តនោះត្រូវបានអនុវត្តកម្រិតណា? តើគេរៀបចំថវិការដ្ឋសភារបៀបណា? តើសមាជិករដ្ឋសភាមានអភ័យឯកសិទ្ធិកម្រិតណា? មានសិទ្ធិ កាតព្វកិច្ច និងទំនួលខុសត្រូវអ្វីខ្លះ? តើពួកគេមានសមត្ថភាពកម្រិតណា? តើក្នុងទំនាក់ទំនងរវាងរដ្ឋាភិបាល និងរដ្ឋសភាមានតុល្យភាពដែរឬទេ? ហេតុអ្វីបានជាគណបក្សមានឥទ្ធិពលខ្លាំងលើតំណាងរាស្ត្រ ហើយតើគួរដោះស្រាយបញ្ហានេះបែបណា?

ទន្ទឹមនឹងនេះដែរ យើងនឹងវិភាគផងដែរថា តើមានការប្រកួតប្រជែងនយោបាយតាមរយៈរដ្ឋសភាយ៉ាងដូចម្ដេច? តើព្រឹត្តិការណ៍ថ្ងៃទី០៥-០៦ ខែកក្កដា ឆ្នាំ១៩៩៧ បានជះឥទ្ធិពលអ្វីខ្លះទៅលើរដ្ឋសភា? តើច្បាប់ធម្មនុញ្ញបន្ថែមឆ្នាំ២០០៤ ដែលនាំទៅដល់ការបោះឆ្នោតកញ្ចប់ បានផ្ដល់ផលវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះចំពោះសង្គមជាតិ និងរដ្ឋសភា? តើការកែសម្រួលលក្ខខណ្ឌរដ្ឋធម្មនុញ្ញក្នុងការរៀបចំរចនាសម្ព័ន្ធរដ្ឋសភា និងការបង្កើតរដ្ឋាភិបាលពីសំឡេង ២/៣ មក ៥០%+១ បាននាំមកនូវអត្ថប្រយោជន៍អ្វីខ្លះ? ហើយចុងក្រោយ យើងនឹងពិនិត្យមើលថា តើរដ្ឋសភាមានតួនាទី និងសិទ្ធិអំណាចអ្វីខ្លះ? ហើយរដ្ឋសភាអាចអនុវត្តតួនាទី និងសិទ្ធិអំណាចទាំងនោះកម្រិតណា?

ចម្លើយចំពោះចំណោទបញ្ហាខាងលើ ត្រូវបានបកស្រាយនៅក្នុងនិក្ខេបបទនេះ ដែលចែកជាបួនជំពូក ៖ ជំពូកទី១ ស្ដីពីរដ្ឋសភាកម្ពុជា មុនឆ្នាំ១៩៩៣ ក្នុងបរិបទប្រវត្តិសាស្ត្រ និងនយោបាយ ដែលសិក្សាពីបុព្វបទនៃការកកើតរដ្ឋសភានៅកម្ពុជា ដោយឆ្លុះបញ្ចាំងទៅលើទិដ្ឋភាពប្រវត្តិសាស្ត្រនៃរបបគ្រប់គ្រងសង្គមកម្ពុជាមុនសង្គ្រាមលោកលើកទី២ និងពីប្រវត្តិ ហើយនិងការវិវត្តនៃស្ថាប័នរដ្ឋសភា ពីឆ្នាំ១៩៤៦ រហូតដល់ឆ្នាំ១៩៩៣។ ជំពូកទី ២ សិក្សាពីការបោះឆ្នោត និងការរៀបចំរចនាសម្ព័ន្ធរដ្ឋសភាក្រោយឆ្នាំ ១៩៩៣ ដោយឆ្លុះបញ្ចាំងពីបម្រែបម្រួលនយោបាយឆ្ពោះទៅកាន់ការបោះឆ្នោតឆ្នាំ១៩៩៣ ដំណើរការ

ប្រជាធិបតេយ្យក្រោយកិច្ចព្រមព្រៀង និងការបោះឆ្នោតជាបន្តបន្ទាប់ចាប់ឆ្នាំ១៩៩៣ មក និងការរៀបចំរចនាសម្ព័ន្ធរដ្ឋសភា។ ជំពូកទី ៣ សិក្សាពីការប្រព្រឹត្តិទៅនៃរដ្ឋសភាកម្ពុជា ដោយផ្តោតទៅលើការប្រជុំរបស់រដ្ឋសភា ដំណើរការនីតិកម្មរបស់រដ្ឋសភា ការរៀបចំថវិការដ្ឋសភា សមាជិករដ្ឋសភា និងទំនាក់ទំនងរបស់រដ្ឋសភាជាមួយស្ថាប័ននានា។ ជំពូកទី៤ សិក្សាពីរដ្ឋសភាកម្ពុជាក្នុងបរិបទនយោបាយ និងការអនុវត្តគោលការណ៍បែងចែកអំណាច ដោយបង្ហាញពីការប្រកួតប្រជែងនយោបាយតាមរយៈរដ្ឋសភា ឆ្នាំ១៩៩៣-១៩៩៨, រដ្ឋសភា និងព្រឹត្តិការណ៍ថ្ងៃទី០៥-០៦ កក្កដា ១៩៩៧, ការបោះឆ្នោតកញ្ចប់នៃច្បាប់ធម្មនុញ្ញបន្ថែម និងវិសោធនកម្ម ៥០%+១ និងសិទ្ធិអំណាចរបស់រដ្ឋសភា។

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងវិភាគយ៉ាងល្អិតល្អន់រួចមក យើងរកឃើញថា ៖

- ការបំភ័យ និងការគំរាមក្នុងការបោះឆ្នោតនៅកម្ពុជា តែងកើតមានតាំងពីទសវត្សរ៍ឆ្នាំ១៩៥០ មកម្ល៉េះ។
- ទស្សនៈបុគ្គលនិយម «ភ្នំមួយមិនអាចមានខ្លាពីរ», «មានឯងអត់អញ-មានអញអត់ឯង» របស់អ្នកនយោបាយខ្មែរ គឺជាមូលហេតុនាំឱ្យមានព្រឹត្តិការណ៍បង្ហូរឈាម ថ្ងៃទី០៥-០៦ ខែកក្កដា ឆ្នាំ១៩៩៧ និងវិបត្តិនយោបាយក្រោយៗមកទៀត។
- បញ្ហាកូរ៉ុម ដែលរដ្ឋសភាជួបប្រទះក្នុងនីតិកាលទី១ គឺដោយសារការបែងចែកមិនដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។
- វិសោធនកម្មរដ្ឋធម្មនុញ្ញ ៥០%+១ ជាការសងសឹករបស់លោក សម រង្ស៊ី ចំពោះ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងហ៊ុនស៊ិនប៊ិច ដែលនេះជាទម្លាប់ទូទៅនៃមេដឹកនាំខ្មែរ។
- កម្រិតខ្ពស់នៃបុគ្គលនិយមជាអ្នកកំណត់នូវបុគ្គលិកលក្ខណៈនៃនយោបាយកម្ពុជា ហើយជូនកាលកំហឹងបុគ្គល និងសមត្ថភាពមិនស្របច្បាប់នៃអ្នកនយោបាយកំពូលៗ បានធ្វើឱ្យរាំងស្ទះប្រព័ន្ធនយោបាយប្រទេសកម្ពុជាទាំងមូល។
- អ្នកនយោបាយខ្មែរភាគច្រើនមិនទុកចិត្តគ្នា ទោះជាអ្នកដែលនៅក្នុងបក្សជាមួយគ្នាក៏ដោយ។ ភាពមិនទុកចិត្តគ្នានេះ បានស្តែងឱ្យឃើញតាមរយៈប្រព័ន្ធដឹកនាំបែបសហនាយករដ្ឋមន្ត្រី (១៩៩៣-១៩៩៨) សហរដ្ឋមន្ត្រី (១៩៩៣-២០០៦) និងការបោះឆ្នោតកញ្ចប់ដោយលើកដៃ និងគ្មានការបកស្រាយ (ប្រជាធិបតេយ្យបែបចាប់បង្ខំ) (២០០៤ និង២០០៨)។
- នៅកម្ពុជា កត្តាបុគ្គលមានឥទ្ធិពលលើនយោបាយ, កត្តានយោបាយមានឥទ្ធិពលលើច្បាប់។

# ABSTRACT

National Assembly of Cambodia (NA) was first established in 1947 as the result of the State's first Constitution which was promulgated by the King on 06 May 1947. Since 1947, there have been 12 elections taken place in Cambodia including: First election on 21 December 1947, Second election on 09 September 1951, Third election on 11 September 1955, Fourth election on 23 March 1958, Fifth election on 10 June 1962, Sixth election on 11 September 1966, Seventh election on 03 September 1972, Eighth election on 20 March 1976, Ninth election on 01 May 1981, Tenth election on 23-28 may 1993, Eleventh election on 26 July 1998 and Twelfth election on 27 July 2003.

The purpose of this dissertation is to dig out the history of the Cambodian National Assembly and its evolution since 1947 until 2008. The research questions raised in this dissertation include: difficulties that NA faced at its starting point, how NA was structured, the NA's quorum issue and solution, NA's law making process, the effectiveness of the laws passed by NA, NA's budget arrangement, the immunities, rights, obligation, responsibilities and education level of NA's members, the relationship balance between NA and government, party's influence over NA's members and solution, 5-6 July event's impact over NA, additional constitutional law and package vote's impact, advantage and disadvantage of the 50%+1 constitutional amendment, and roles and power of NA.

The answers to the problematic issues were made in this dissertation which was divided into four chapters as follow: Chapter One: Cambodian national assembly before 1993 in the context of history and politics, reflecting on precondition of the establishment of the assembly with focussing on historical aspect of the Cambodian government systems before World War I and the history of the assembly and its evolution since 1947 to 1993. Chapter Two: Post-1993 elections and national assembly's organizational structure, examining on Cambodian political change toward 1993 elections, democratization process and post-1993 elections, and national assembly's organizational structure arrangement. Chapter Three: The functioning of the national assembly, focusing on national assembly's meeting procedures, legislation, national assembly's budgeting, national assembly's members and national assembly's external relations. Chapter Four: Cambodian national assembly in political context and implementation of principle of power separation, analysing the political contest in the national assembly from 1993-1998, the 5-6 July 1997 event's effects to the national assembly, package vote in framework of the additional constitutional law and 50%+1 amendment of the constitution, and the power of the national assembly.

This dissertation found that:

- Politicians' individualism of "There shall not be two tigers in one mountain" and "It shall not be for you and me, it shall be only for me or for you" were the main cause of blooding 5-6 July 1997 event and that of other political crisis.
- The lack of quorum of NA in the first term resulted from power separation system of Cambodia.
- The 50%+1 amendment of the constitution is a kind of revenge of Sam Rainsy to Prince Norodom Ranariddh and FUNCINPEC, that is a kind of habit of Cambodian leaders.
- Cambodian politics is really characterized by a very high degree of personalization and that sometimes the personal animosities and legal battles of leading politicians can paralyze the whole political system.
- Cambodia politicians do not usually trust each other even though they are in the same party. This can be seen through co-prime ministers (1993-1998) and co-ministers (1993-2006) in government system and package vote by show of hands (forced democracy) in 2004 and in 2008.
- In Cambodia, individual influences politics, politics influence legal system.

# សេចក្ដីសង្ខេប

រដ្ឋសភានៃប្រទេសកម្ពុជាមានកំណើតដំបូងនៅឆ្នាំ១៩៤៧ ដែលជាផ្លែផ្កានៃរដ្ឋធម្មនុញ្ញដំបូងបំផុតរបស់ប្រទេស ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៤៧។ ចាប់ពីឆ្នាំ១៩៤៧ មក ប្រទេសកម្ពុជាមានការរៀបចំការបោះឆ្នោតជ្រើសតាំងរដ្ឋសភាជាបន្តបន្ទាប់ ចំនួន ១២ លើក រួមមាន ៖ លើកទី១ បោះឆ្នោតនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៧, លើកទី២ បោះឆ្នោតនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៥១, លើកទី៣ បោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥, លើកទី៤ បោះឆ្នោតនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៨, លើកទី៥ បោះឆ្នោតនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៦២, លើកទី៦ បោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៦៦, លើកទី៧ បោះឆ្នោតនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៧២, លើកទី៨ បោះឆ្នោតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦, លើកទី៩ បោះឆ្នោតនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៨១, លើកទី១០ បោះឆ្នោតនៅថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣, លើកទី១១ បោះឆ្នោតនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ និងលើកទី១២ បោះឆ្នោតនៅថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០០៣។

តាមរយៈនៃការបោះឆ្នោតក្នុងដំណាក់កាលជាបន្តបន្ទាប់នេះ រដ្ឋសភាត្រូវបានបង្កើតឡើងតាមបែបផែននយោបាយ និងសារជាតិនៃរបបគ្រប់គ្រងនីមួយៗ។ តួនាទី សិទ្ធិ អំណាច និងសារៈសំខាន់នៃស្ថាប័ននេះ ថ្វីបើមានចែងក្នុងទ្រឹស្តី និងចារឹកក្នុងច្បាប់កំពូលរបស់ប្រទេសក្តី ក៏ការអនុវត្តជាក់ស្តែង មានលក្ខណៈផ្ទុយស្រឡះ ដែលគេសង្កេតឃើញថា ស្ថាប័នរដ្ឋសភាខ្មែរគ្រប់សម័យកាល ព្រំដែនសិទ្ធិអំណាចរបស់ខ្លួន ស្ថិតក្នុងភាពស្រពេចស្រពិលមួយ ដែលពិបាកកំណត់។

ចំណោទបញ្ហាជាច្រើនត្រូវបានលើកឡើងពាក់ព័ន្ធនឹងដំណើរការ និងការប្រព្រឹត្តិទៅនៃរដ្ឋសភាកម្ពុជាក្រោយឆ្នាំ១៩៩៣។ ដូចយើងដឹងហើយថា រដ្ឋសភាកម្ពុជាត្រូវបានបង្កើតឡើងបន្ទាប់ពីប្រទេសជាតិរួចផុតសង្គ្រាមស៊ីវិល ព្រមទាំងជម្លោះមនោគមវិជ្ជានៃមហាអំណាចខាងក្រៅ។ ក្នុងន័យនេះ យើងនឹងពិនិត្យមើលថា តើក្នុងដំណាក់កាលដំបូងនៃការកកើតឡើងនេះ រដ្ឋសភាកម្ពុជាបានពើបប្រទះនូវការលំបាកអ្វីខ្លះ? តើការរៀបចំរចនាសម្ព័ន្ធរដ្ឋសភាផ្អែកលើមូលដ្ឋានអ្វី? តើហេតុអ្វីបានជារដ្ឋសភាជួបការលំបាកក្នុងបញ្ហាកូរ៉ុមប្រជុំ ហើយគេដោះស្រាយបញ្ហាទាំងនោះដោយរបៀបណា?

ជាមួយគ្នានេះដែរ យើងនឹងពិនិត្យមើលថា តើដំណើរការនីតិកម្មប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើច្បាប់ដែលរដ្ឋសភាបានអនុម័តនោះត្រូវបានអនុវត្តកម្រិតណា? តើគេរៀបចំថវិការដ្ឋសភារបៀបណា? តើសមាជិករដ្ឋសភាមានអភ័យឯកសិទ្ធិកម្រិតណា? មានសិទ្ធិ កាតព្វកិច្ច និងទំនួលខុសត្រូវអ្វីខ្លះ? តើពួកគេមានសមត្ថភាពកម្រិតណា? តើក្នុងទំនាក់ទំនងរវាងរដ្ឋាភិបាល និងរដ្ឋសភា មានតុល្យភាពដែរឬទេ? ហេតុអ្វីបានជាគណបក្សមានឥទ្ធិពលខ្លាំងលើតំណាងរាស្ត្រ ហើយតើគួរដោះស្រាយបញ្ហានេះបែបណា?

ទន្ទឹមនឹងនេះ យើងក៏បានវិភាគផងដែរថា តើមានការប្រកួតប្រជែងនយោបាយតាមរយៈរដ្ឋសភាយ៉ាងដូចម្ដេច? តើព្រឹត្តិការណ៍ថ្ងៃទី០៥-០៦ ខែកក្កដា ឆ្នាំ១៩៩៧ បានជះឥទ្ធិពលអ្វីខ្លះទៅលើរដ្ឋសភា? តើរដ្ឋធម្មនុញ្ញបន្ថែមឆ្នាំ២០០៤ ដែលនាំទៅដល់ការបោះឆ្នោតកញ្ចប់ បានផ្ដល់ផលវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះចំពោះសង្គមជាតិ និងរដ្ឋសភា? តើការកែសម្រួលលក្ខខណ្ឌរដ្ឋធម្មនុញ្ញក្នុងការរៀបចំរចនាសម្ព័ន្ធរដ្ឋសភា និងការបង្កើតរដ្ឋាភិបាលពីសំឡេង ២/៣ មក ៥០%+១ បាននាំមកនូវអត្ថប្រយោជន៍អ្វីខ្លះ? ហើយចុងក្រោយ យើងពិនិត្យមើលថា តើរដ្ឋសភាមានតួនាទី និងសិទ្ធិអំណាចអ្វីខ្លះ? ហើយរដ្ឋសភាអាចអនុវត្តតួនាទី និងសិទ្ធិអំណាចទាំងនោះកម្រិតណា?

ក្នុងនិក្ខេបបទនេះ ចែកចេញជាបួនជំពូក។

<u>ជំពូកទី១</u> សិក្សាពីប្រវត្តិរដ្ឋសភាកម្ពុជា មុនឆ្នាំ១៩៩៣ ដោយឆ្លុះបញ្ចាំងតាមរយៈទិដ្ឋភាពប្រវត្តិសាស្ត្រ និងនយោបាយ។ ចាប់ពីឆ្នាំ១៩៤៧ មកដល់ឆ្នាំ១៩៨១ ប្រទេសកម្ពុជាមានការបោះឆ្នោតជ្រើសតាំងរដ្ឋសភារដ្ឋសភាចំនួន ៩ លើក ដូចខាងក្រោម ៖

លើកទី ១ ៖ រដ្ឋសភា ឆ្នាំ១៩៤៧-១៩៥១ បោះឆ្នោតនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៧ ដែលមានគណបក្សចំនួន ០៥ ចូលរួម ក្នុងនោះ គណបក្សចំនួន ០៣ គឺសុទ្ធតែដឹកនាំដោយព្រះអង្គម្ចាស់នៃខ្សែរាជវង្ស ដែលត្រូវបានបង្កើតតាំងពីការបោះឆ្នោតជ្រើសរើសសភាធម្មនុញ្ញ ឆ្នាំ១៩៤៦ មកម្ល៉េះ។ គណបក្សទាំងបីនោះ គឺ គណបក្សប្រជាធិបតេយ្យដឹកនាំដោយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស គណបក្សសេរីភាពដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម នរិន្ទដេត និងគណបក្សចម្រើនជាតិ ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា។ រីឯគណបក្សពីរទៀត ត្រូវបង្កើតឡើងនៅខែកញ្ញា ឆ្នាំ១៩៤៦ គឺគណបក្សខេមរបុណ្ណាការ ដឹកនាំដោយលោក លន់ នល់ និងគណបក្សសហជីពជាតិ (ឬគណៈរួមជាតិខេមរៈ) ដឹកនាំដោយលោក យឹម ទិត ដែលទ្រទ្រង់ថវិកាផ្ទាល់ខ្លួនរបស់គាត់ និងប្អូនជីដូនមួយឈ្មោះ តាយេបផាយ ហ៊ីបតុលា ម៉ាឆ្វា (Tayebbhay Hiptoola Machhwa) ដែលជាមូស្លីម និងជាអ្នកជំនួញលេចធ្លោរម្នាក់កូនកាត់ខ្មែរ-ឥណ្ឌា។ ទន្ទឹមនឹងនោះ ក៏មានបេក្ខជនឯកច្ឆន្ទចូលរួមប្រកួតប្រជែងផងដែរ។ លទ្ធផលនៃការបោះឆ្នោតនេះ គឺ គណបក្សប្រជាធិបតេយ្យបានទទួលសំឡេងគាំទ្រចំនួន ៥៤ កៅអី ក្នុងចំនួនកៅអីទាំងអស់ ដែលមាន ៧៥។ គណបក្សសេរីភាពបានទទួលចំនួន ២១ កៅអី។

លើកទី ២ ៖ រដ្ឋសភា ឆ្នាំ១៩៥១-១៩៥៣ បោះឆ្នោតនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៥១។ ការបោះឆ្នោតលើកនេះ មានគណបក្សចំនួន ៤ ប៉ុណ្ណោះ ដែលបានទទួលអាសនៈនៅក្នុងរដ្ឋសភា ដែលមានចំនួន ៧៨ អាសនៈ ក្នុងនោះ រួមមានគណបក្សប្រជាធិបតេយ្យ ទទួលបានសន្លឹកឆ្នោតចំនួន ៤៥% បាន ៥៤ អាសនៈ គណបក្សសេរីភាព ទទួលបានសន្លឹកឆ្នោត ២៣% បាន ១៨ អាសនៈ គណបក្សវៀសានមានជ័យ ទទួលបានសន្លឹកឆ្នោតចំនួន ៥,១% បាន ០៤ អាសនៈ និងគណបក្សខេមរប៉ុណ្ណាការ ទទួលបានសន្លឹកឆ្នោតចំនួន ២,៦% បាន២ អាសនៈ។ ដោយឡែក គណបក្សផ្សេងៗទៀត ពុំបានទទួលអាសនៈនៅក្នុងរដ្ឋសភាទេ។

លើកទី ៣ ៖ រដ្ឋសភា ឆ្នាំ១៩៥៥-១៩៥៨ បោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥។ នេះជាការបោះឆ្នោតចុងក្រោយក្នុងទសវត្សឆ្នាំ១៩៥០ ដោយមានគណបក្សច្រើនចូលរួមប្រកួតប្រជែងដោយសេរី ហើយសម្តេច នរោត្តម សីហនុ បានប្រកាសចាកចេញពីរាជបល្ល័ង្ក ដើម្បីចូលប្រឡូកក្នុងនយោបាយ។ ការដាក់រាជ្យរបស់សម្តេច នរោត្តម សីហនុ គឺដោយព្រះអង្គមានការជឿជាក់ថា ព្រះអង្គមានប្រជាប្រិយភាពខ្លាំងជាងគណបក្សផ្សេងៗ។

លទ្ធផលនៃការបោះឆ្នោតនេះ គណបក្សសង្គមបានឈ្នះដាច់ដោយបានទទួលអាសនៈទាំងអស់នៅក្នុងរដ្ឋសភា ដែលមានចំនួន ៩១ ដោយទទួលបានសន្លឹកឆ្នោត ចំនួន ៦៣០.៦២៥ សន្លឹក ស្មើនឹង ៨៣%, គណបក្សប្រជាធិបតេយ្យទទួលបាន ៩៣.៩១៩ សំឡេង ស្មើនឹង ១២%, គណបក្សប្រជាជនទទួលបាន ២៩.៥០៩ សំឡេង ស្មើនឹង ៤% គណបក្សសេរីភាព ទទួលបាន ៥.៤៨៨ សំឡេង, គណបក្សតម្កើងប្រជាជាតិខ្មែរ ទទួលបាន ១.១៥៤ សំឡេង, គណបក្សខ្មែរឯករាជ្យទទួលបាន ៧៩៤ សំឡេង គណបក្សពលករខ្មែរ បានទទួល ២៨៩ សំឡេង និងបេក្ខជនឯកច្ឆន្ទបានទទួល ១៨៦ សំឡេង។

លើកទី ៤ ៖ រដ្ឋសភា ឆ្នាំ១៩៥៨-១៩៦២ បោះឆ្នោតនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៨។ លទ្ធផលនៃការបោះឆ្នោតនៅឆ្នាំ១៩៥៨ បានផ្តល់ឱ្យបេក្ខជន ដែលធ្លាប់ជាអតីតសមាជិកគណបក្សប្រជាធិបតេយ្យ បានទទួលអាសនៈទាំងអស់ជាថ្មីម្តងទៀត ចំនួន ៦១ នៅក្នុងរដ្ឋសភា។ ក្នុងចំណោមពួកគេមានអ្នកសង្គមនិយមល្បីៗ ដូចជា ចៅ សេង ហ៊ូ យន់ និង ហ៊ូ នឹម ដែលពេលក្រោយមក ហ៊ូ យន់ និង ហ៊ូ នឹម ក្លាយជាមេដឹកនាំនៅរបបកម្ពុជាប្រជាធិបតេយ្យ។ ជាមួយគ្នានេះ ក៏មានលោក ឡុង បូរ៉េត ដែលជាមេជាវីស្តាំនិយមវ័យក្មេងមួយរូប និង ចេង ហេង ដែលជាពាណិជ្ជករនៅខេត្តកណ្តាល។ លោក ឡុង បូរ៉េត គឺជានាយករដ្ឋមន្ត្រីចុងក្រោយបំផុតនៃរបបសាធារណរដ្ឋខ្មែរ រីឯលោក ចេង ហេង គឺជាប្រមុខរដ្ឋទី១ របស់របបសាធារណរដ្ឋខ្មែរនេះ។

លើកទី ៥ ៖ រដ្ឋសភា ឆ្នាំ១៩៦២-១៩៦៦ បោះឆ្នោតនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៦២។ ការបោះឆ្នោតនាឆ្នាំ១៩៦២ ជាដំណាក់កាលដ៏សំខាន់មួយក្នុងជំនាន់សម្តេច នរោត្តម សីហនុ។ ការបោះឆ្នោតនេះបានធ្វើឡើងបន្ទាប់ពីសង្គ្រាមបានផ្ទុះឡើងនៅវៀតណាមខាងត្បូងរវាងទាហានយួន ដែលស្មោះត្រង់ចំពោះរដ្ឋាភិបាល ង៉ោ ឌិញយៀម ដែលកាន់ជើងសហរដ្ឋអាមេរិក និងទាហានយួនដទៃទៀត ដែលព្យាយាមបង្រួបបង្រួមប្រទេសក្រោមការដឹកនាំរបស់ពួកកុម្មុយនីស្តនៅទីក្រុងហាណូយ។ ការបោះឆ្នោតនេះស្រដៀងគ្នាទៅនឹងការបោះឆ្នោត ឆ្នាំ១៩៥៨ ដែលគណបក្សសង្គមតែងតាំងបេក្ខជនបោះឆ្នោតក្នុងបញ្ជីតែមួយសម្រាប់មណ្ឌលបោះឆ្នោតនីមួយៗ។ ពេលនោះ គឺគ្មានគណបក្សប្រឆាំងទេ។ សភាបានកើនចំនួនសមាជិកពី៦១ ទៅដល់៧៧ រូប ហើយគណបក្សសង្គមបានទទួលអាសនៈទាំងអស់នៅក្នុងរដ្ឋសភា។

លើកទី ៦ ៖ រដ្ឋសភា ឆ្នាំ១៩៦៦-១៩៧២ បោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៦៦។ ការបោះឆ្នោតឆ្នាំ១៩៦៦ ជាពេលដែលសម្តេច នរោត្តម សីហនុ ស្ទើរតែត្រូវបង្អាក់មិនឱ្យធ្វើអ្វីកើត ដោយ

សត្រូវទាំងឡាយនៅក្នុង និងនៅក្រៅប្រទេស ដែលកំពុងប្រយុទ្ធប្រឆាំងព្រះអង្គ។ នៅឆ្នាំ១៩៦៥ ព្រះអង្គទទួលរៀបចំធ្វើសន្និសីទប្រជាជនឥណ្ឌូចិនមួយនៅភ្នំពេញ ដោយបានអញ្ជើញរណសិរ្សរំដោះ វៀតណាមខាងត្បូង រដ្ឋាភិបាលវៀតណាមខាងជើង និងប៉ាថេតឡាវកុម្មុយនីស្ត ក្នុងឋានៈជាអ្នកចូលរួមតែម្នាក់ឯង។ ក្រុមស្តាំនិយមពុំសប្បាយចិត្តរឿងនេះឡើយ។ ព្រះអង្គបានសម្រេចព្រះទ័យមិនប្រឈមតតាំងដោយចេញមុខទេ ហើយបានប្រកាសជាលើកដំបូងថា ព្រះអង្គនឹងលែងចាត់តាំងបេក្ខជនផ្លូវការរបស់គណបក្សសង្គមក្នុងការបោះឆ្នោតទៀតហើយ។

នេះជាលើកទីមួយហើយ ក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាឯករាជ្យ ដែលអ្នកណាៗ ក៏អាចឈរឈ្មោះឱ្យគេបោះឆ្នោតចូលក្នុងរដ្ឋសភាដែរ។ នេះជាការបោះឆ្នោតដ៏មានតម្លៃបំផុតដែលប្រទេសជាតិមិនធ្លាប់បានជួបប្រទះសោះពីមុនមក។ បេក្ខជនក្នុងគណបក្សសង្គមរាស្ត្រនិយម ៤២៥ រូប បានប្រកួតប្រជែងគ្នាដណ្តើមយកអាសនៈក្នុងរដ្ឋសភាចំនួន ៨២។ បេក្ខជនអភិរក្សនិយម ដែលមានលុយច្រើនបានដើរទិញសន្លឹកឆ្នោត ហើយបានទទួលជ័យជម្នះយ៉ាងលើសលប់មួយក្នុងមណ្ឌលភាគច្រើន លើកលែងតែមណ្ឌលមួយចំនួនចេញ ដែលជនកុម្មុយនីស្តបីនាក់បានជាប់ឆ្នោតចូលក្នុងរដ្ឋសភាដដែល គឺ ខៀវ សំផន ហ៊ូ យន់ និង ហ៊ូ នឹម ដែលត្រូវជាប់ឆ្នោតដោយងាយស្រួលក្នុងមណ្ឌលរបស់គាត់ បើទោះជាមានការតាមធ្វើទុក្ខបុកម្នេញរបស់ប៉ូលីសក៏ដោយ។

លើកទី ៧ ៖ សភាសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧២-១៩៧៥ បោះឆ្នោតនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៧២។ ក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ រយៈពេល២ឆ្នាំ គឺ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ ១៩៧២ រដ្ឋធម្មនុញ្ញថ្មីមួយនៃប្រទេសកម្ពុជាត្រូវបានប្រកាសឱ្យប្រើ ដែលជាការត្រួសត្រាយផ្លូវសម្រាប់ការបោះឆ្នោតប្រធានាធិបតី និងនាំប្រទេសជាតិឆ្ពោះទៅកាន់របបប្រធានាធិបតីនិយមតាមបែបប្រជាធិបតេយ្យ ដែលមានបាវចនា សេរីភាព សមភាព ភាតរភាព អភិវឌ្ឍន៍ និងសុភមង្គល។ ក្រោយរដ្ឋធម្មនុញ្ញចូលជាធរមាន មានការបោះឆ្នោតសំខាន់ៗបីត្រូវបានធ្វើឡើង គឺការបោះឆ្នោតជ្រើសរើសប្រធានាធិបតី នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧២ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ១៩៧២ និងការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧២។

នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៧២ គេបានរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រតាមការគ្រោងទុក។ មានគណបក្សនយោបាយតូចៗជាច្រើនចូលរួមប្រកួតប្រជែង រួមទាំងគណបក្សដែលជាសាខាផង។ តែគណបក្សប្រឆាំងធំៗមិនចូលរួមប្រកួតទេ។ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៧២ ទ្រង់ សិរិមតៈ បានប្រកាសដកគណបក្សមិនចូលរួមប្រកួតដោយថា ច្បាប់បោះឆ្នោតមិនស្របតាមរដ្ឋធម្មនុញ្ញ និងគ្មានលក្ខណៈប្រជាធិបតេយ្យ។ គណបក្សប្រជាធិបតេយ្យរបស់ អ៊ិន តាំ ក៏ដកខ្លួនថយដែរ។ ការធ្វើពហិការរបស់គណបក្សទាំងពីរនេះ បានទុកឱកាសឱ្យគណបក្សសង្គមសាធារណរដ្ឋរបស់ លន់ នល់ ប្រមូលយកអាសនៈទាំងអស់ គឺ ១២៦។ លោក លន់ នល់ អះអាងថា ប្រជាជនចំនួន ៧៨% បានចុះឈ្មោះបោះឆ្នោត ហើយ ៩០% បោះឆ្នោតឱ្យគណបក្សគាត់។

លើកទី ៨ ៖ សភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យ បោះឆ្នោតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦។ បន្ទាប់ពីបានទទួលជោគជ័យលើរបបសាធារណរដ្ឋខ្មែរ ពួកខ្មែរក្រហមបានរៀបចំរបៀបផែន និងគោលនយោបាយគ្រប់គ្រងប្រទេសទៅតាមគោលគំនិតដ៏ចម្លែករបស់ខ្លួន។ ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ សំណើរដ្ឋធម្មនុញ្ញមួយត្រូវបានអនុម័តដោយសមាជិកចំនួនមួយពាន់នាក់ក្នុងមហាសន្និបាតជាតិនៅទីក្រុងភ្នំពេញ ហើយត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦។

រដ្ឋធម្មនុញ្ញបានបង្កើតសភាតំណាងប្រជាជន មានសមាជិកចំនួន ២៥០នាក់ ដែលក្នុងនោះ ១៥០នាក់ តំណាងឱ្យវណ្ណៈកសិករ ៥០នាក់ តំណាងឱ្យវណ្ណៈកម្មករ និងពលករ និង ៥០នាក់ទៀត តំណាងឱ្យកងទ័ពបដិវត្តន៍កម្ពុជា។ យោងតាមស្មារតីនៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យបានកំណត់ថា សមាជិកសភាតំណាងប្រជាជនកម្ពុជា ត្រូវបានប្រជាជនជ្រើសរើសដោយការបោះឆ្នោតទូទាំងប្រទេស ដោយផ្ទាល់ និងដោយសម្ងាត់ក្នុងរយៈកាលប្រាំឆ្នាំម្តង។ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ គេបានរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងប្រជាជន ដែលមានចំនួន ២៥០អាសនៈ ក្នុងនោះ ១៥០នាក់ តំណាងកសិករ ៥០នាក់ តំណាងឱ្យកម្មករ និងពលករ និង ៥០នាក់ទៀត តំណាងឱ្យកងទ័ព។ ប៉ុន្តែ មកដល់ពេលនេះ ការស្រាវជ្រាវរបស់យើងមិនទាន់រកឃើញបញ្ជីឈ្មោះសមាជិកសភាតំណាងប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យនៅឡើយ។

លើកទី ៩ ៖ រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា (ឆ្នាំ១៩៨១-១៩៩៣) បោះឆ្នោតនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៨១។ រដ្ឋសភាដែលជា «អង្គការកំពូលនៃអំណាចរដ្ឋ» បានត្រូវបោះឆ្នោតដោយផ្ទាល់សម្រាប់អាណត្តិប្រាំឆ្នាំ។ សមាជិករដ្ឋសភាតំណាងឱ្យប្រជាជនដែលត្រូវបានជ្រើសរើសតាមគោលការណ៍បោះឆ្នោតជាសកល ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសឆ្នោតជាសម្ងាត់។ ការបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភានៃរបបថ្មីត្រូវបានប្រព្រឹត្តទៅនៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៨១ ដែលមានចំនួន ២០ មណ្ឌលបោះឆ្នោត។ ប្រជាជនចំនួន ៩៧.៨២% នៃប្រជាជនទូទាំងប្រទេសបានទៅបោះឆ្នោត។ រដ្ឋសភានេះមានអាសនៈ ទាំងអស់ចំនួន ១១៧ ដែលក្នុងនោះរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានតែងតាំងបេក្ខជនរបស់ខ្លួនចំនួន ១៤៨ រូប។ នៅក្នុងសម័យប្រជុំនីតិកាលទី១ ដែលបានប្រព្រឹត្តឡើងចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ១៩៨១ រដ្ឋសភាបានអនុម័តនូវរដ្ឋធម្មនុញ្ញថ្មី និងបោះឆ្នោតជ្រើសរើសសមាជិកអង្គការរដ្ឋ ដែលធ្វើឡើងក្រោមបញ្ញត្តិរបស់រដ្ឋធម្មនុញ្ញ។

ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបើកសម័យប្រជុំវិសាមញ្ញមួយ ដើម្បីពិនិត្យ និងអនុម័តមាត្រាទាំងឡាយនៃរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវធ្វើវិសោធនកម្ម។ ចាប់ពីពេលនោះមក ប្រទេសកម្ពុជាមានឈ្មោះជាផ្លូវការថា «រដ្ឋកម្ពុជា»។ រដ្ឋសភា ដែលកើតចេញពីការបោះឆ្នោតនាខែឧសភា ឆ្នាំ១៩៨១ បានបន្តអាណត្តិរហូតដល់ការបោះឆ្នោតឆ្នាំ១៩៩៣ គ្រាន់តែប្តូរឈ្មោះទៅតាមឈ្មោះប្រទេស គឺពី «រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា» ទៅជា «រដ្ឋសភានៃរដ្ឋកម្ពុជា»។

ជំពូកទី២ សិក្សាពីការបោះឆ្នោត និងការរៀបចំរចនាសម្ព័ន្ធរដ្ឋសភា ក្រោយឆ្នាំ១៩៩៣។ ក្នុងការសិក្សានេះ ស្មេរបានបង្ហាញពីបម្រែបម្រួលនយោបាយនៅកម្ពុជាឆ្ពោះទៅកាន់ការបោះឆ្នោត ឆ្នាំ១៩៩៣ ជាពិសេសពាក់ព័ន្ធនឹងការចរចាសន្តិភាពនេះនៅកម្ពុជា។

មាគ៌ាទៅរកសន្តិភាពមានរយៈពេលយ៉ាងយូរ ហើយវាក៏យូរហួសនិស្ស័យដែរ ចំពោះការឈឺចាប់របស់ប្រជាពលរដ្ឋខ្មែរ។ ទីបំផុត ការទន្ទឹងរបស់ប្រជាពលរដ្ឋខ្មែរក៏បានមកដល់។ កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា ត្រូវបានចុះហត្ថលេខាដោយភាគីខ្មែរទាំងបួន ដោយមានការចូលរួមពីបណ្តាប្រទេសជាងម្ភៃ និងប្រទេសហត្ថលេខីចំនួន១៨ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលជាទូទៅយើងហៅថា «កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស»។ កិច្ចព្រមព្រៀងនេះបានកំណត់ពីការរៀបចំការបោះឆ្នោត ពីបទឈប់បាញ់ ការដកអាវុធ ការកាត់រំសាយកងទ័ព ការបោះឆ្នោត មាតុភូមិនិវត្តន៍ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែង អធិបតេយ្យភាព ឯករាជ្យ និងបូរណភាពទឹកដីកម្ពុជាឡើងវិញ។

បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសត្រូវបានចុះហត្ថលេខា ព្រះមហាក្សត្រ និងសម្តេចព្រះរាជអគ្គមហេសី ព្រមទាំងព្រះរាជវង្សានុវង្សយាងចូលប្រទេស ដោយមានការស្វាគមន៍យ៉ាងគគ្រឹកគគ្រេង រីឯខៀវ សំផន និងសុន សេន ត្រូវបានស្វាគមន៍ដោយបាតុកម្មប្រឆាំង។ ចំណែកអង្គការសហប្រជាជាតិបានបញ្ជូនយូណាមិុច (UNAMIC) ដើម្បីរៀបចំឱ្យមានប្រតិបត្តិការអ៊ុនតាក់។ ភាគីបីក្នុងចំណោមភាគី ៤ បានអនុវត្តតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ពិសេសការឈប់បាញ់ និងការប្រមូលផ្តុំកងទ័ព ដើម្បីកាត់រំសាយ ការបើកតំបន់ និងស្ថាប័នឱ្យអ៊ុនតាក់ត្រួតពិនិត្យ។

ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា «UNTAC» ត្រូវបានបង្កើតឡើងដោយរួមមានទាំងផ្នែកយោធា និងផ្នែកស៊ីវិល ដើម្បីរៀបចំការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពនេះ។ តួនាទីដ៏ចម្បងរបស់ UNTAC គឺការរៀបចំឱ្យមានការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា ដើម្បីជាការបើកឱកាសឱ្យប្រជាជនកម្ពុជាកំណត់នូវជោគវាសនារបស់ខ្លួនដោយខ្លួនឯង។

ផ្លែផ្កានៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៣បាននាំទៅដល់ការបោះឆ្នោតជាតិសំខាន់ៗចំនួន ៣ លើក គឺ ៖ លើកទី១ គឺការបោះឆ្នោតជ្រើសរើសសភាធម្មនុញ្ញ ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញ រួចប្រែក្លាយខ្លួនជារដ្ឋសភាជាតិ។ ការបោះឆ្នោតនេះបានប្រព្រឹត្តទៅ នៅថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣។ ក្នុងចំណោមគណបក្សទាំង២០ មានតែគណបក្សបួនប៉ុណ្ណោះដែលបានទទួលអាសនៈនៅក្នុងរដ្ឋសភា ក្នុងនោះគឺ គណបក្សហ៊្វុនស៊ិនប៉ិចបានទទួល ៥៨ អាសនៈ គណបក្សប្រជាជនកម្ពុជា បានទទួល ៥១ អាសនៈ គណបក្សប្រជាធិបតេយ្យ សេរីនិយមព្រះពុទ្ធសាសនាបានទទួល ១០ អាសនៈ និងគណបក្សម៉ូលីណាកា និងអ្នកតស៊ូខ្មែរ ដើម្បីសេរីភាព បានទទួល ១ អាសនៈ។

ការបោះឆ្នោតលើកទី២ បានប្រព្រឹត្តនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨។ នេះជាការបោះឆ្នោតមួយត្រូវបានអ្នកប្រវត្តិសាស្ត្រកត់ត្រាទុកថា ជាអច្ឆរិយៈនៅទន្លេមេគង្គ ដោយសារការបោះឆ្នោតនេះត្រូវបានរៀបចំឡើងក្រោយពីការប្រយុទ្ធរង្គោះរង្គើក្រុងភ្នំពេញបានតែមួយឆ្នាំប៉ុណ្ណោះ។ មានគណបក្សនយោបាយចំនួន ៣៩ បានមកចុះឈ្មោះប្រកួតប្រជែង និងមានបេក្ខជនសរុបចំនួន ៦.៨៥០ នាក់ (គិតទាំងបេក្ខជនពេញសិទ្ធិ និងបេក្ខជនបម្រុង)។

លទ្ធផលនៃការបោះឆ្នោតសម្រាប់ អាសនៈ ទាំង ១២២ ក្នុងរដ្ឋសភា គឺគណបក្សប្រជាជនកម្ពុជាបាន ៦៤ អាសនៈ ចំណែកឯគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលធ្លាប់ទទួលអាសនៈច្រើនជាងគេ កាលពីការបោះឆ្នោតឆ្នាំ១៩៩៣ គឺបានទទួលតែអាសនៈ ចំនួន ៤៣ប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ គណបក្សសមរង្ស៊ី ដែលបង្កើតឡើងក្រោយការបែកបាក់ជាមួយគណបក្ស ហ្វ៊ុនស៊ិនប៉ិចនោះ បានទទួលអាសនៈដល់ទៅ ១៥ អាសនៈ។ ចំពោះគណបក្សផ្សេងៗទៀត ពុំមានសំឡេងគាំទ្រគ្រប់គ្រាន់ក្នុងការទទួលអាសនៈនៅតាមមណ្ឌលនីមួយៗ ដែលខ្លួនឈរឈ្មោះនោះទេ។

ការបោះឆ្នោតលើកទី៣ បានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០០៣។ ចំនួនគណបក្សចូលរួមការបោះឆ្នោតបានធ្លាក់ចុះមកត្រឹម ២៣ ប៉ុណ្ណោះ បើប្រៀបធៀបនឹងចំនួនគណបក្សនយោបាយចូលរួមបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី២ឆ្នាំ១៩៩៨មាន រហូតដល់ទៅ៣៩។ ក្នុងឆ្នាំ២០០៣នេះដែរ ចំនួនអាសនៈតំណាងរាស្ត្រនៃ ២៤ ខេត្ត ក្រុង ទូទាំងប្រទេសកើនដល់ ១២៣ អាសនៈ ពោលគឺបន្ថែមមួយអាសនៈទៀតនៃមណ្ឌលទើបបង្កើតថ្មី គឺខេត្តឧត្តរមានជ័យ។ លទ្ធផល គឺគណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈចំនួន ៧៣ ខណៈដែលគណបក្សហ្វ៊ុនស៊ិនប៉ិចទទួលបាន ២៦ អាសនៈ និងគណបក្សសមរង្ស៊ី ទទួលបាន ២៤ អាសនៈ។ ដោយឡែក គណបក្សផ្សេងៗទៀតមិនបានទទួលអាសនៈណាមួយនៅក្នុងរដ្ឋសភានោះទេ។

ក្នុងជំពូកទី២ នេះ យើងក៏សិក្សាយ៉ាងលម្អិតផងដែរ អំពីការរៀបចំរចនាសម្ព័ន្ធរដ្ឋសភា។ រដ្ឋសភាដែលកើតចេញពីការបោះឆ្នោតក្រោយកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ចំនួនបីអាណត្តិមកនេះ ជាតុចាំបាច់ដើម្បីឱ្យរដ្ឋសភាអាចដំណើរការបានក្រោយការបោះឆ្នោត គឺការចរចាព្រមព្រៀងគ្នារវាងគណបក្សដែលឈ្នះឆ្នោត ដើម្បីរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច ការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានរដ្ឋសភា និងការជ្រើសរើសគណៈកម្មការជំនាញនានា រួមទាំងបញ្ហាមួយចំនួន ដើម្បីឱ្យក្លាយជារដ្ឋសភាពេញលក្ខណៈតាមផ្លូវច្បាប់។

ការរៀបចំរចនាសម្ព័ន្ធដឹកនាំនៅក្នុងរដ្ឋសភាកម្ពុជានីតិកាលទី១ ក៏ដូចជានីតិកាលទី២ និងទី៣ គឺអាស្រ័យដោយការចរចានយោបាយសុទ្ធសាធ។ ក្រោយការបោះឆ្នោតជាតិម្តងៗ តែងតែមានភាពជាប់គាំងនយោបាយជាប់ជានិច្ច។ រចនាសម្ព័ន្ធដឹកនាំរដ្ឋសភានីតិកាលនីមួយៗ ជាលទ្ធផលនៃការតថ្លៃអំណាចរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច។ ក្នុងនីតិកាលទី១ គណបក្សហ្វ៊ុនស៊ិនប៉ិចមានសំឡេងភាគច្រើននៅក្នុងរដ្ឋសភា តែគណបក្សនេះមិនបានទទួលតំណែងជាប្រធានរដ្ឋសភា

នោះទេ ផ្ទុយទៅវិញ ក្នុងនីតិកាលទី២ និងពាក់កណ្ដាលនីតិកាលទី៣ គណបក្សហ៊្វុនស៊ិនប៉ិច ដែលមានសំឡេងតិចជាងគណបក្សប្រជាជនកម្ពុជា បែរជាបានទទួលតំណែងជាប្រធានរដ្ឋសភា ដោយសារសំឡេងបង្គ្រប់របស់ខ្លួន។ ប៉ុន្តែ បន្ទាប់ពីភាពជាប់គាំងនយោបាយត្រូវបានដោះស្រាយ និងបង្កើតបាននូវរចនាសម្ព័ន្ធរដ្ឋសភា និងរដ្ឋាភិបាលរួច គណបក្សហ៊្វុនស៊ិនប៉ិចជាបណ្ដើរៗ មិនមានឥទ្ធិពលអ្វីនៅក្នុងរដ្ឋសភាទៀតទេ។

ជំពូកទី៣ សិក្សាពីការប្រព្រឹត្តិទៅនៃរដ្ឋសភាកម្ពុជា ដោយធ្វើការវិភាគ និងវែកញែកអំពីការប្រជុំរបស់រដ្ឋសភា ដំណើរការនីតិកម្មរបស់រដ្ឋសភា ការរៀបចំថវិការដ្ឋសភា សមាជិករដ្ឋសភា និងទំនាក់ទំនងរបស់រដ្ឋសភាជាមួយស្ថាប័ននានា។ ជាការណ៍ពិត ក្នុងសង្គមប្រជាធិបតេយ្យ ការប្រជុំរបស់រដ្ឋសភាមានសារៈសំខាន់ណាស់ ព្រោះវាជាឱកាស ដែលសមាជិករដ្ឋសភាដែលជាស្ពានចម្លងឆន្ទៈរបស់ប្រជារាស្ត្រជាម្ចាស់ឆ្នោត ជជែកវែកញែកពីកម្មវិធីនយោបាយល្អៗ ដើម្បីដោះស្រាយបញ្ហាសង្គម លើកកម្ពស់កម្រិតជីវភាព និងការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋ លើកកម្ពស់លទ្ធផលប្រជាធិបតេយ្យ ពង្រឹងនីតិរដ្ឋ និងការអនុវត្តច្បាប់។ ទន្ទឹមនឹងនេះ ការប្រជុំគឺជាឱកាសដែលសមាជិករដ្ឋសភាបញ្ចេញមតិជាចំហ ដើម្បីឱ្យរាជរដ្ឋាភិបាលបំពេញតួនាទីរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ មានតម្លាភាព និងទប់ស្កាត់ ឬបញ្ចប់ទង្វើ ដែលផ្ដល់ផលប៉ះពាល់ដល់ផលប្រយោជន៍ជាតិ។

ប៉ុន្តែ បញ្ហាខ្វះក្វ័រុមរបស់រដ្ឋសភានាអណត្តិទី១ ដែលធ្វើឱ្យរដ្ឋសភាខកខានការងាររបស់ខ្លួនយ៉ាងច្រើន។ ចំណុចនេះ យើងត្រូវតែលាតត្រដាងសម្រាប់ជាមេរៀនដល់កូនខ្មែរជំនាន់ក្រោយ។ ជាមួយគ្នានេះ មានការលើកឡើងជាញឹកញាប់ថា សម័យប្រជុំរបស់រដ្ឋសភា ដើរតួនាទីគ្រាន់តែជាវេទិកាជជែកកម្សាន្ត ឬជាវេទិកាការពារខ្លួន និងគណបក្សតែប៉ុណ្ណោះ។ ជាងនេះទៅទៀត ក្នុងដំណើរការនីតិកម្មរបស់រដ្ឋសភា អ្នកតំណាងរាស្ត្រត្រូវដើរតួនាទីជាខ្សែចម្លងឆន្ទៈរាស្ត្រ និងពាំនាំឆន្ទៈទាំងនោះទៅពិចារណានៅក្នុងរដ្ឋសភា តែផ្ទុយទៅវិញ មានច្បាប់ច្រើនណាស់ដែលអ្នកតំណាងរាស្ត្រត្រូវបានគេរិះគន់ថា មិនសូវយកចិត្តទុកដាក់ចំពោះឆន្ទៈរាស្ត្រ ដែលជាម្ចាស់ឆ្នោតទេ។

មាត្រា ៥១ ថ្មីនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានកំណត់ឱ្យមានស្ថាប័នកំពូលបីដាច់ពីគ្នា គឺ ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការ ហើយស្ថាប័នទាំងបីនេះមានតួនាទី និងអំណាចខុសៗ គ្នា។ រដ្ឋធម្មនុញ្ញបានកំណត់ថា ព្រឹទ្ធសភា និងរដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ រដ្ឋសភាដើរតួនាទីសំខាន់ណាស់ក្នុងដំណើរការនីតិកម្មនៅកម្ពុជា។

យោងវាក្យខ័ណ្ឌ១ មាត្រា៨១ នៃរដ្ឋធម្មនុញ្ញបានចែងថា "រដ្ឋសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ"។ សេចក្ដីស្នើថវិការបស់រដ្ឋសភាត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ហើយបញ្ជូនទៅក្រសួងមានសមត្ថកិច្ច ដើម្បីបញ្ចូលក្នុងគម្រោងថវិកាជាតិ។ របាយការណ៍ទូទាត់ចំណាយថវិកា

របស់រដ្ឋសភាពាល់ងំណាច់ឆ្នាំ ត្រូវដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យសម្រេច ហើយត្រូវបញ្ជូនទៅក្រសួងមានសមត្ថកិច្ច ដើម្បីរៀបចំបញ្ចូលក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ។

ក្នុងជំពូកនេះ ក៏បានបង្ហាញពីទំនាក់ទំនងប្រកបដោយភាពប្រទាក់ក្រឡារបស់រដ្ឋសភាជាមួយស្ថាប័នព្រះមហាក្សត្រ, រាជរដ្ឋាភិបាល, គណបក្សនយោបាយ, ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត, សង្គមស៊ីវិល និងទំនាក់ទំនងអន្តរជាតិ។ ក្នុងទំនាក់ទំនងជាមួយព្រះមហាក្សត្រ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងថា ព្រះមហាក្សត្រទ្រង់ទាក់ទងជាមួយព្រឹទ្ធសភា និងរដ្ឋសភាដោយព្រះរាជសារ។ ព្រះរាជសារនេះ ព្រឹទ្ធសភា និងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាបានឡើយ។ ប៉ុន្តែ ចាប់តាំងពីឆ្នាំ១៩៩៣ មកគេកម្រឃើញមានព្រះរាជសាររបស់ព្រះអង្គផ្ញើទៅរដ្ឋសភា ឬព្រឹទ្ធសភាណាស់។ ទំនាក់ទំនងដ៏សំខាន់មួយរវាងព្រះមហាក្សត្រ និងរដ្ឋសភា គឺព្រះរាជតួនាទីរបស់ព្រះអង្គក្នុងការកោះប្រជុំរដ្ឋសភា ដើម្បីឱ្យរដ្ឋសភាបើកសម័យប្រជុំដំបូងរបស់ខ្លួនហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត។

ដោយឡែកក្នុងទំនាក់ទំនងជាមួយរដ្ឋាភិបាល គឺស្ថិតនៅលើវិស័យសំខាន់ពីរ គឺវិស័យផ្តល់ព័ត៌មាន និងវិស័យត្រួតពិនិត្យ។ ក្នុងវិស័យផ្តល់ព័ត៌មាន គឺអំណាចទាំងពីរនេះ ចាំបាច់ត្រូវផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។ រីឯក្នុងវិស័យត្រួតពិនិត្យវិញ រដ្ឋសភាត្រូវធ្វើការត្រួតពិនិត្យចំពោះរាជរដ្ឋាភិបាលតាមធម្មតា គឺពិនិត្យក្នុងបច្ចុប្បកាល(កំពុងអនុវត្ត) ចំពោះបណ្តាសកម្មភាពដែលរដ្ឋាភិបាលបានអនុវត្ត ឬបណ្តាគោលនយោបាយដែលបានលើកឡើងដោយរដ្ឋាភិបាល។ នៅក្នុងការពិនិត្យនោះ រដ្ឋសភាមានសមត្ថកិច្ចវិនិច្ឆ័យទៅលើសកម្មភាព ឬទៅលើគោលនយោបាយទាំងនោះ។ ការវិនិច្ឆ័យនោះអាចនាំដល់ការដាក់ទណ្ឌកម្មមួយ គឺអនុម័តញត្តិបន្ទោស។ តាមការដាក់ស្តែងការអនុម័តញត្តិបន្ទោសចំពោះរដ្ឋាភិបាលនឹងនាំដល់ការលាលែងរបស់គណៈរដ្ឋមន្ត្រីទាំងមូល។

ចំពោះទំនាក់ទំនងជាមួយសង្គមស៊ីវិល រដ្ឋសភាមិនត្រូវព្រងើយកន្តើយចំពោះសារៈសំខាន់របស់សង្គមស៊ីវិលក្នុងការតាក់តែងច្បាប់នោះទេ។ បើនិយាយឱ្យចំ រដ្ឋសភាធ្វើច្បាប់នានា គឺសម្រាប់ផលប្រយោជន៍របស់សង្គមទាំងមូល។ ក្នុងការតាក់តែងច្បាប់ សមាជិកសភាគឺជាអ្នកតំណាងឱ្យទស្សនៈពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួន និងលើកទស្សនៈទាំងនោះជម្រាបជូនសភា។ ដូច្នេះ ការទទួលយកមតិរបស់សង្គមស៊ីវិលរបស់សភា គឺជាគន្លឹះមួយសម្រាប់សមាជិកសភា ដើម្បីបំពេញតួនាទីខ្លួនជាតំណាងពលរដ្ឋ។

រដ្ឋសភា ជាស្ថាប័នកំពូលមួយរបស់រដ្ឋ ក៏ដូចស្ថាប័នព្រឹទ្ធសភា និងរាជរដ្ឋាភិបាលដែរ ស្ថាប័ននេះមានទំនាក់ទំនងជាមួយស្ថាប័នសភាបរទេសក្នុងន័យរឹតចំណងមិត្តភាពរវាងប្រជារាស្ត្រនិងប្រជារាស្ត្រ និងចំណងការងាររវាងរដ្ឋសភា និងរដ្ឋសភា។ ក្នុងកិច្ចដំណើរការទំនាក់ទំនងអន្តរជាតិនេះ រដ្ឋធម្មនុញ្ញត្រង់មាត្រា៨៧ បានប្រគល់ភារកិច្ចនេះ ជូនប្រធានរដ្ឋសភាដោយផ្ទាល់ដោយបានចែងថា ៖ «ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអញ្ញត្តិច្បាប់ និងសេចក្តីសម្រេចចិត្តទាំងឡាយដែលរដ្ឋសភាអនុម័ត ធ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា»។ ក្នុងន័យនេះ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រង់ប្រការ៦ថ្មី ដែលចែងអំពីការបង្កើតគណៈកម្មការ

ជំនាញផ្សេងៗបានកំណត់ឱ្យគណៈកម្មការទី៥ ទទួលបន្ទុកប៉ារងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជាមួយនឹងកិច្ចការមួយចំនួនទៀត។ គណៈកម្មការនេះ មានភារកិច្ចធំពីរ គឺ ៖ ត្រួតពិនិត្យកិច្ចការបរទេសរបស់រដ្ឋាភិបាល និងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នសភាបរទេសនិងអង្គការអន្តរជាតិនានា។ កិច្ចទំនាក់ទំនងរដ្ឋសភាមានប្រភេទជាទ្វេភាគី និងពហុភាគី។

<u>ជំពូកទី៤</u> សិក្សាពីរដ្ឋសភាកម្ពុជាក្នុងបរិបទនយោបាយ និងការអនុវត្តគោលការណ៍បែងចែកអំណាច ដែលក្នុងនោះ បង្ហាញពីការប្រកួតប្រជែងនយោបាយតាមរយៈរដ្ឋសភា ឆ្នាំ១៩៩៣-១៩៩៨, រដ្ឋសភា និងព្រឹត្តិការណ៍ថ្ងៃទី០៥-០៦ កក្កដា ១៩៩៧, ការបោះឆ្នោតកញ្ចប់នៃច្បាប់ធម្មនុញ្ញបន្ថែម និងវិសោធនកម្ម ៥០%+១ និងចុងក្រោយសិក្សាវិភាគអំពីសិទ្ធិអំណាចរបស់រដ្ឋសភា។

ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ដំណើរនយោបាយកម្ពុជា នៅតែស្ថិតលើផ្លូវគ្រោះថ្នាក់នៅឡើយ។ ការប្រកួតប្រជែងនយោបាយគ្នារវាងគណបក្សធំទាំងពីរ គឺ ប្រ.ជ. និងហ៊្វុនស៊ិនប៉ិច បានកើតមានគ្រប់ទីកន្លែងតាំងពីថ្នាក់មូលដ្ឋានរហូតដល់ស្ថាប័នជាតិធំៗ រួមទាំងរដ្ឋសភាផង។ ជាក់ស្តែង ក្រៅពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ដែលរដ្ឋសភាបានចូលពាក់ព័ន្ធយ៉ាងជ្រៅក្នុងព្រឹត្តិ-ការណ៍នេះ ក្នុងចន្លោះឆ្នាំ១៩៩៤ ដល់ដើមឆ្នាំ១៩៩៧ មានព្រឹត្តិការណ៍ធំៗបីទៀត ដែលរដ្ឋសភាត្រូវបានគេស្តីបន្ទោសថា ស្ថិតក្រោមការបញ្ជារបស់រដ្ឋាភិបាល និងចំណុះគណបក្សនយោបាយ។ ព្រឹត្តិការណ៍ទាំងបីនោះ គឺទី១- ករណីបណ្តេញលោក សម រង្ស៊ី ចេញពីតំណែងជារដ្ឋមន្ត្រីហិរញ្ញវត្ថុ និងពីរដ្ឋសភា ទី២- ករណីដកអភ័យឯកសិទ្ធិរបស់ព្រះអង្គម្ចាស់ នរោត្តម សិរីវុឌ្ឍ និងទី៣- គឺព្រឹត្តិការណ៍គប់គ្រាប់បែកនៅមុខរដ្ឋសភា ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧។

ព្រឹត្តិការណ៍ដ៏សំខាន់មួយចំនួននាឆ្នាំ១៩៩៦ ដែលរួមមានទាំងការប្រកាសដកខ្លួនរបស់គណបក្សហ៊្វុនស៊ិនប៉ិចចេញពីរាជរដ្ឋាភិបាល និងការផ្តាច់ខ្លួនរបស់ក្រុមខ្មែរក្រហម អៀង សារី ចេញពីអង្គការចាត់តាំងនយោបាយរបស់ខ្មែរក្រហមក្បាលរឹង បានជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ព្រឹត្តិការណ៍ជាច្រើនទៀតនាឆ្នាំ១៩៩៧ ហើយមានរឿងរ៉ាវកើតឡើងហួសពីការស្មានទុកទៅទៀត។

ប្រភពដើមនៃជម្លោះក្នុងរដ្ឋាភិបាលចម្រុះ ដែលមានគណបក្សធំពីរកាន់អំណាច «គណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សប្រជាជនកម្ពុជា» ផ្តើមចេញពីការដាក់យុទ្ធសាស្ត្រដ៏ខុសឆ្គងក្នុងន័យបង្កហេតុ ដែលព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងមន្ត្រីជាន់ខ្ពស់មួយចំនួនដែលមានកក្តីភាពនឹងព្រះអង្គបានលើកឡើងក្នុងសិក្ខាសាលានៅដើមឆ្នាំ១៩៩៦ នាក្រុងព្រះសីហនុ។ យុទ្ធសាស្ត្រដែលគេបានលើកឡើងក្នុងសិក្ខាសាលានោះគឺ «យុទ្ធសាស្ត្រតុល្យភាពកម្លាំង និងការប្រឈមមុខ»។

ក្រោយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ ព្រះរាជាណាចក្រកម្ពុជាបានជួបនឹងវិបត្តិនយោបាយជាថ្មីម្តងទៀត គឺមិនអាចរៀបចំបង្កើតរដ្ឋសភា និងរាជរដ្ឋាភិបាលអាណត្តិថ្មីបានឡើយ។ វិបត្តិនេះ គឺផ្តើមចេញពីបញ្ហាគណបក្សដែលឈ្នះឆ្នោតមិនអាចបង្កើតរដ្ឋាភិបាល

តែម្នាក់ឯងបាន ពោលគឺ តម្រូវឱ្យមានការចូលរួមពីសំណាក់គណបក្សនយោបាយមួយក្នុងចំណោមគណបក្សនយោបាយពីរ ដែលទទួលបានអាសនៈនៅក្នុងរដ្ឋសភា ទាមទារបង្កើតរដ្ឋាភិបាលចម្រុះ។

វិបត្តិនយោបាយនោះបានអូសបន្លាយជិតមួយឆ្នាំ ហើយបានបញ្ចប់ទៅវិញនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤ បន្ទាប់ពីមានជំនួបមួយរវាងលោក ហ៊ុន សែន និងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ នៅជំណាក់វាលស្បូវ បានឯកភាពធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នា ដើម្បីបង្កើតសភាជាតិ និងរាជរដ្ឋាភិបាលអាណត្តិទី៣ ព្រមទាំងបានឯកភាពជ្រើសរើសយកនីតិវិធីបោះឆ្នោតជាកញ្ចប់ក្នុងការជ្រើសតាំងរចនាសម្ព័ន្ធដឹកនាំរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តដល់រដ្ឋាភិបាលក្នុងពេលតែមួយក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា តាមរយៈការធ្វើច្បាប់ធម្មនុញ្ញបន្ថែម។ ច្បាប់ធម្មនុញ្ញបន្ថែមនេះមានចំនួន ៧ មាត្រា។ ច្បាប់ធម្មនុញ្ញបន្ថែមនេះ បានបង្កើតឱ្យមានភាពចម្រូងចម្រាស់ និងមន្ទិលសង្ស័យលើស្រទាប់អ្នកនយោបាយ អ្នកច្បាប់ ក៏ដូចជាសង្គមស៊ីវិលអំពីអធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមនេះ។

នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៦ គណបក្សសម រង្ស៊ី បានដាក់ចេញនូវសំណើដ៏គួរឱ្យភ្ញាក់ផ្អើលមួយ ដែលស្នើឱ្យប្រើប្រាស់សំឡេង ៥០%+១ នៅក្នុងការបង្កើតរដ្ឋាភិបាល។ សំណើនេះត្រូវបានគាំទ្រភ្លាមៗដោយ ប្រ.ជ. តែហ្វ៊ុនស៊ិនប៉ិចហាក់ដូចជាមានភាពស្ទាក់ស្ទើរ។ គេមើលឃើញថា ប្រ.ជ. មានប្រៀបយ៉ាងខ្លាំងចំពោះសំណើបែបនេះ។ វិសោធនកម្មនេះ ត្រូវបានរដ្ឋសភាអនុម័តយល់ព្រមនៅក្នុងសម័យប្រជុំពេញអង្គនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៦។

ឥឡូវសូមត្រឡប់មកនិយាយពីអំណាចរដ្ឋសភាវិញម្តង។ រដ្ឋសភា គឺជាអង្គការកំពូលមួយក្នុងចំណោមអង្គការទាំងបីរបស់រដ្ឋ។ តាមស្មារតីនៃរដ្ឋធម្មនុញ្ញ រដ្ឋសភាមានអំណាចដ៏ធំធេងបំផុតក្នុងវិស័យច្បាប់ ក៏ដូចជាការត្រួតពិនិត្យលើស្ថាប័ននីតិប្រតិបត្តិ។ ថ្វីបើគេដឹងរួចមកហើយថា រដ្ឋសភាជាបឋម គឺជាក្រុមមួយដែលធ្វើច្បាប់ តែប្រការសំខាន់គេត្រូវទទួលស្គាល់ថា ស្ថាប័ននេះមានអំណាចទៅលើវិស័យសំខាន់ៗជាច្រើនទៀត ដូចជា អំណាចសើរើរដ្ឋធម្មនុញ្ញ, អំណាចក្នុងការងារហិរញ្ញវត្ថុ, អំណាចយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ, អំណាចក្នុងការផ្តល់សេចក្តីទុកចិត្ត ត្រួតពិនិត្យ និងរំលាយរដ្ឋាភិបាល, អំណាចតែងតាំង និងបណ្តេញមន្ត្រីជាន់ខ្ពស់នៃរដ្ឋបាលអចិន្ត្រៃយ៍ និងអំណាចក្នុងនយោបាយការបរទេស។

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងវិភាគយ៉ាងល្អិតល្អន់រួចមក យើងរកឃើញថា ៖

- ការបំភ័យ និងការគំរាមក្នុងការបោះឆ្នោតនៅកម្ពុជា តែងកើតមានតាំងពីទសវត្សរ៍ឆ្នាំ១៩៥០មកម្ល៉េះ។
- ទស្សនៈបុគ្គលនិយម «ភ្នំមួយមិនអាចមានខ្លាពីរ», «មានឯងអត់អញ-មានអញអត់ឯង» របស់អ្នកនយោបាយខ្មែរ គឺជាមូលហេតុនាំឱ្យមានព្រឹត្តិការណ៍បង្ហូរឈាម ថ្ងៃទី០៥-០៦ ខែកក្កដា ឆ្នាំ១៩៩៧ និងវិបត្តិនយោបាយក្រោយៗមកទៀត។

- បញ្ហាក្រុម ដែលរង្វេសភាជួបប្រទះក្នុងនីតិកាលទី១ គឺដោយសារការបែងចែកមិនដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។
- វិសោធនកម្មរដ្ឋធម្មនុញ្ញ ៥០%+១ ជាការសងសឹករបស់លោក សម រង្ស៊ី ចំពោះ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងហ៊ុនស៊ិនប៊ិច ដែលនេះជាទម្លាប់ទូទៅនៃមេដឹកនាំខ្មែរ។
- កម្រិតខ្ពស់នៃបុគ្គលនិយមជាអ្នកកំណត់នូវបុគ្គលិកលក្ខណៈនៃនយោបាយកម្ពុជា ហើយជូនកាលកំហឹងបុគ្គល និងសមរភូមិស្របច្បាប់នៃអ្នកនយោបាយកំពូលៗ បានធ្វើឱ្យរាំងស្ទះប្រព័ន្ធនយោបាយប្រទេសកម្ពុជាទាំងមូល។
- អ្នកនយោបាយខ្មែរភាគច្រើនមិនទុកចិត្តគ្នា ទោះជាអ្នកដែលនៅក្នុងបក្សជាមួយគ្នាក៏ដោយ។ ភាពមិនទុកចិត្តគ្នានេះ បានស្តែងឱ្យឃើញតាមរយៈប្រព័ន្ធដឹកនាំបែបសហនាយករដ្ឋមន្ត្រី (១៩៩៣-១៩៩៨) សហរដ្ឋមន្ត្រី (១៩៩៣-២០០៦) និងការបោះឆ្នោតកញ្ចប់ដោយលើកដៃ និងគ្មានការបកស្រាយ (ប្រជាធិបតេយ្យបែបចាប់បង្ខំ) (២០០៤ និង២០០៨)។
- នៅកម្ពុជា កត្តាបុគ្គលមានឥទ្ធិពលលើនយោបាយ, កត្តានយោបាយមានឥទ្ធិពលលើច្បាប់។

# SUMMARY

National Assembly of Cambodia (NA) was first established in 1947 as the result of the State's first Constitution which was promulgated by the King on 06 May 1947. Since 1947, there have been 12 elections taken place in Cambodia including: First election on 21 December 1947, Second election on 09 September 1951, Third election on 11 September 1955, Fourth election on 23 March 1958, Fifth election on 10 June 1962, Sixth election on 11 September 1966, Seventh election on 03 September 1972, Eighth election on 20 March 1976, Ninth election on 01 May 1981, Tenth election on 23-28 may 1993, Eleventh election on 26 July 1998 and Twelfth election on 27 July 2003.

Through subsequent elections, NA has been established in form and essence in accordance with each State's regime. Even though the roles, privileges, powers necessity of this institution have been stated in theories as well as in constitution as the supreme of the country, practically, the roles, privileges, powers necessity have been unclear.

The processes and functioning of the NA have been still problematic. As we know, NA was formed after the country was released from civil war and political ideology of external powers. In this regard, we will examine the difficulties faced by NA in the first establishment, the basis that NA is structured, and difficulties of meeting quorum faced by NA how was it solved?

At the same time, we examine the legislation processes of NA, how the laws passed NA implemented, NA's budgets, immunities, privileges, obligation, responsibilities and education level of Members of NA, the relationship balance between the government and NA, and party's influence on Members of NA and how to solve it.

Meanwhile, we also analyze the political competition within NA, the impact of July 05-06, 1997 event on NA, social negative and positive impact of 2004 Additional Constitutional Law which led to package votes; the impact of constitutional amendment from 2/3 to 50 % +1 in structuring and forming NA and government, and the NA's roles and responsibilities.

This dissertation is divided into four chapters:

**Chapter 1: History of NA before 1993 in Historical and Political Context.**

Since 1947 to 1981, Cambodia had nine NA elections as follows:

**First election**: NA of 1947-1951, the elections held on 21 December 1947, which participated by five political parties, in which the three political parties led by the Royal family. The three parties were created since the election of the Constituent Assembly in 1946. These three parties were the Democrats Party led by Prince Sisowath Yuthvung, Liberal Party led by Prince Norodom Norindeth and National Progress Party, led by Prince Norodom Montana. The other two parties were established in September 1946, namely Khemarak Ponnaka Party led by Mr. Lon Nol and the National Union

Party led by Mr. Khim Tith, supported by his own budget and his cousin, Tayebbhay Hiptoola Machhwa, a Muslim and a prominent businessman Indian-Khmer hybrid. In addition, there were also other independent participated in this election as well. The result of this election is Democrats Party got 54 seats out of 75 seats, and Liberal Party received 21 seats.

**Second Election:** NA of 1951-1953, the election held on September 09, 1951. In this election, only four parties who won seats in parliament with 78 seats, in which Democrats Party took 45% of votes with 54 seats, Liberal Party took 23% votes with 18 seats, Issan Meanchey Party took 5.1% of votes with 04 seats, and Khemarak Ponnaka Party took 2.6 % of votes with 2 seats. The other parties did not get any seats in the Assembly.

**Third Election:** NA of 1955-1958, the election held on September 11, 1955. This was the last election in 1950s with participation of many parties to compete freely and Samdech Norodom Sihanouk announced abdication and involved in politics. King Norodom Sihanouk abdicated because he was confident that he was more popular than the other parties.

The results of this election, Sangkum Reastr Niyum Party won all 91 seats in NA, accounted 630,625 votes, equal to 83 %, Democrats took 93,919 votes, equal to 12 %, People's Party took 29,509 votes, equal to 4 %, Liberal Party tool 5,488 votes, Khmer National Progress took 1,154 votes, Khmer Independent Party took 794 votes, Khmer Workers' Party took 289 votes, and unanimous candidate received 186 votes.

